ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការ

ទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា

លេខៈ ០៤/០៤ គ.ទ.ក ស.ស.រ

# សេចក្ដីសំរេច

## ស្ដីពី

## ការអនុវត្តកម្មវិធីសិក្សាតាមប្រព័ន្ធក្រេឌីត និង ការផ្ទេរក្រេឌីត

## ប្រធាន គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣០៣/១២៩ ចុះថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០០៣ ស្ដីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦០៣/១២៩ ចុះថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០០៣ ស្ដីពីការតែងតាំងប្រធាន អនុប្រធានអចិន្ត្រៃយ៍ និងសមាជិក នៃគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ១៣ ខែមិថុនា ឆ្នាំ ២០០២ ស្ដីពីលក្ខណៈវិនិច្ឆ័យនៃការបង្កើតសាកលវិទ្យាល័យ
- បានឃើញអនុក្រឹត្យលេខ ៤៦ អនក្រ.បក ចុះថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០០៣ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា
- បានឃើញសេចក្ដីសំរេច លេខ ០២/០៤ គ.ទ.ក ស.ស.រ ចុះថ្ងៃទី ២២ ខែមីនា ឆ្នាំ ២០០៤ ស្ដីពីលក្ខខណ្ឌសំរាប់ការចេញវិញ្ញាបនប័ត្រថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន នៅតាមគ្រឹះស្ថានឧត្តមសិក្សា

# សំរេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**ប្រការ១** : សេចក្តីសំរេចនេះមានគោលបំណង កំណត់អំពីបែបបទនៃការអនុវត្តកម្មវិធីសិក្សា តាមប្រព័ន្ធក្រេឌីត និងការផ្ទេរក្រេឌីតនៅតាមគ្រឹះស្ថានឧត្តមសិក្សានៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

**ប្រការ២** : ប្រព័ន្ធក្រេឌីត គឺជាយន្តការសំរាប់សំរួលដល់ការសិក្សាមិនពេញម៉ោង ឬការបញ្ចូលគ្នានូវការសិក្សាពេញម៉ោងផង និងការសិក្សាមិនពេញម៉ោងផង ។

ការផ្ទេរក្រេឌីត គឺជាការទទួលស្គាល់ជាផ្លូវការរបស់គ្រឹះស្ថានឧត្តមសិក្សាមួយ លើមុខវិជ្ជាទាំងឡាយដែលនិស្សិតបានបញ្ចប់ដោយជោគជ័យ នៅក្នុងគ្រឹះស្ថានឧត្តមសិក្សាមួយផ្សេងទៀត ។

**ប្រការ៣** : មួយឆ្នាំសិក្សាចែកជាពីរឆមាស ។ មួយឆមាស មានចំនួនយ៉ាងតិច ១៥សប្តាហ៍ ដោយមិនគិតពីសប្តាហ៍ប្រលង ។ ចំពោះគ្រឹះស្ថានឧត្តមសិក្សា ដែលធ្វើការបណ្តុះបណ្តាលក្នុងវិស្សមកាល រយៈពេល និង ចំនួនក្រេឌីតបណ្តុះបណ្តាលត្រូវផ្អែកលើអ្វី ដែលត្រូវបានបណ្តុះបណ្តាលនៅក្នុងឆមាសធម្មតា ។

## ជំពូកទី២

## ការសិក្សាតាមប្រព័ន្ធក្រេឌីត

**ប្រការ៤** : កម្មវិធីសិក្សានៅឧត្តមសិក្សា ត្រូវបែងចែកជា ៣ប្រភេទដូចខាងក្រោម :

ក- ការសិក្សាទ្រឹស្តី : មួយក្រេឌីតនៃការសិក្សាទ្រឹស្តី គឺជាការបង្រៀននៅក្នុងថ្នាក់រៀន រយៈ-ពេលមួយម៉ោង ក្នុងមួយសប្តាហ៍ ឬ មានចំនួនមិនតិចជាង ១៥ម៉ោងក្នុងមួយឆមាស ។

ខ- ការសិក្សាប្រតិបត្តិ : មួយក្រេឌីតនៃការសិក្សាប្រតិបត្តិ គឺជាការហ្វឹកហាត់ ឬ ការធ្វើពិសោធន៍នៅក្នុងទីពិសោធន៍ មានរយៈពេលយ៉ាងតិច ២ម៉ោងក្នុងមួយសប្តាហ៍ ឬ មានចំនួន ៣០ម៉ោងយ៉ាងតិចក្នុងមួយឆមាស ។

គ- ការអនុវត្តជាក់ស្តែង : មួយក្រេឌីតនៃការសិក្សាអនុវត្តជាក់ស្តែង គឺជាការបណ្តុះបណ្តាល នៅតាមកសិដ្ឋាន ឬក្រុមហ៊ុន ឬមន្ទីរពេទ្យ ឬកន្លែងអនុវត្តជាក់ស្តែងផ្សេងៗទៀត ដែលមានរយៈពេលយ៉ាងតិច ៣ម៉ោងក្នុងមួយសប្តាហ៍ ឬមានចំនួន ៤៥ម៉ោង យ៉ាងតិចក្នុងមួយឆមាស ។

**ប្រការ៥** : ថ្នាក់បរិញ្ញាប័ត្រ ដែលមានកម្មវិធីសិក្សា ៤ឆ្នាំសិក្សា ដោយរាប់បញ្ចូលទាំងថ្នាក់ឆ្នាំសិក្សាមូលដ្ឋានត្រូវមានចំនួនក្រេឌីតសរុបយ៉ាងតិច ១២០ក្រេឌីត ។ រយៈពេលសិក្សាដែលរាប់ចាប់តាំងពីការចុះឈ្មោះចូលរៀនពីដំបូងទៅមិនឱ្យលើសពី ៦ឆ្នាំ សំរាប់និស្សិតពេញម៉ោង និងមិនឱ្យលើសពី ៨ឆ្នាំ សំរាប់និស្សិតមិនពេញម៉ោង ។

**ប្រការ៦** : ថ្នាក់បរិញ្ញាប័ត្រ ដែលមានកម្មវិធីសិក្សា ៥ឆ្នាំសិក្សា ដោយរាប់បញ្ចូលទាំងថ្នាក់ឆ្នាំសិក្សាមូលដ្ឋានត្រូវមានចំនួនក្រេឌីតសរុបយ៉ាងតិច ១៤០ក្រេឌីត ។ រយៈពេលសិក្សាដែលរាប់ចាប់តាំងពីការចុះឈ្មោះចូលរៀនពីដំបូងទៅមិនឱ្យលើសពី ៧ឆ្នាំ សំរាប់និស្សិតពេញម៉ោង និងមិនឱ្យលើសពី ១០ឆ្នាំ សំរាប់និស្សិតមិនពេញម៉ោង ។

**ប្រការ៧** : ថ្នាក់បរិញ្ញាប័ត្រ ដែលមានកម្មវិធីសិក្សា ៦ឆ្នាំសិក្សា ដោយរាប់បញ្ចូលទាំងថ្នាក់ឆ្នាំសិក្សាមូលដ្ឋានត្រូវមានចំនួនក្រេឌីតសរុបយ៉ាងតិច ១៦០ក្រេឌីត ។ រយៈពេលសិក្សាដែលរាប់ចាប់តាំងពីការចុះឈ្មោះចូលរៀនពីដំបូងទៅមិនឱ្យលើសពី ៨ឆ្នាំ សំរាប់និស្សិតពេញម៉ោង និងមិនឱ្យលើសពី ១២ឆ្នាំ សំរាប់និស្សិតមិនពេញម៉ោង ។

**ប្រការ៨** : ថ្នាក់បរិញ្ញាប័ត្រជាន់ខ្ពស់ ដែលមានកម្មវិធីសិក្សា ២ឆ្នាំសិក្សា ត្រូវមានចំនួនក្រេឌីតសរុប យ៉ាងតិច ៤៥ក្រេឌីតឡើងទៅ ។ រយៈពេលសិក្សា ដែលរាប់ចាប់តាំងពីការចុះឈ្មោះចូលរៀនពីដំបូងទៅមិនឱ្យលើសពី ៤ឆ្នាំ សំរាប់និស្សិតពេញម៉ោង និងមិនឱ្យលើសពី ៦ឆ្នាំ សំរាប់និស្សិតមិនពេញម៉ោង ។

**ប្រការ៩** : ថ្នាក់បរិញ្ញាប័ត្រជាន់ខ្ពស់ ដែលមានកម្មវិធីសិក្សា ៣ឆ្នាំសិក្សា ត្រូវមានចំនួនក្រេឌីតសរុបយ៉ាងតិច ៥៧ក្រេឌីត ឡើងទៅ ។ រយៈពេលសិក្សាដែលរាប់ចាប់តាំងពីការចុះឈ្មោះចូលរៀនពី

ដំបូងទៅមិនឱ្យលើសពី ៦ឆ្នាំ សំរាប់និស្សិតពេញម៉ោង និងមិនឱ្យលើសពី ៨ឆ្នាំ សំរាប់និស្សិតមិនពេញម៉ោង ។

**ប្រការ១០** : ថ្នាក់បណ្ឌិត ត្រូវមានកម្មវិធីសិក្សាស្រាវជ្រាវយ៉ាងតិច៣ឆ្នាំសិក្សាឡើងទៅ និងត្រូវមានចំនួនក្រេឌីតសរុប យ៉ាងតិច ៥៤ក្រេឌីត ឡើងទៅ ។ រយៈពេលសិក្សាដែលរាប់ចាប់តាំងពីការចុះឈ្មោះចូលរៀនពីដំបូងទៅមិនឱ្យលើសពី ៨ឆ្នាំ ។ ក្នុងករណីផ្សេងពីនេះត្រូវមានការយល់ព្រមពី គណៈ-កម្មការវិទ្យាសាស្ត្ររបស់គ្រឹះស្ថានឧត្តមសិក្សានោះ ។

## ជំពូកទី៣
## រចនាសម្ព័ន្ធកម្មវិធីសិក្សាសំរាប់ថ្នាក់បរិញ្ញាប័ត្រ

**ប្រការ១១** : រចនាសម្ព័ន្ធកម្មវិធីសិក្សាចែកជាពីរក្រុមធំៗ ។ ក្រុមទី១ គឺជាការអប់រំទូទៅ (ថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន) និងក្រុមទី២ គឺជាការអប់រំជំនាញ ។ ចំនួនក្រេឌីតនៃក្រុមនីមួយៗត្រូវបានកំណត់ក្នុងប្រការ ១២ និង ១៣ ។

**ប្រការ១២** : ថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន : មុខវិជ្ជានៅក្នុងឆ្នាំសិក្សាមូលដ្ឋាន ត្រូវអនុលោមទៅតាមសេចក្តីសំរេចលេខ ០២/០៤ គ.ទ.ក ស.ស.រ ចុះថ្ងៃទី ២២ ខែមីនា ឆ្នាំ ២០០៤ ស្តីពីលក្ខខណ្ឌសំរាប់ការចេញវិញ្ញាបនប័ត្រថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន នៅតាមគ្រឹះស្ថានឧត្តមសិក្សា ។ ចំនួនក្រេឌីតសរុបនៃថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន មិនត្រូវតិចជាង ៣០ក្រេឌីត ។

**ប្រការ១៣** : ការអប់រំជំនាញ : មុខវិជ្ជាជំនាញ (Major Subjects) រាប់បញ្ចូលទាំងមុខវិជ្ជាស្នូល (Core Major Subjects) មុខវិជ្ជាគ្រឹះនៃឯកទេសណាមួយ (Basic Major Subjects) ឬមុខវិជ្ជានៅក្នុងឯកទេសណាមួយ (Elective Major Subjects) ។ មុខវិជ្ជាជំនាញសង្កត់ធ្ងន់លើចំណេះដឹង ការយល់ដឹង និងការអនុវត្តជាក់ស្តែង ។ ចំនួនក្រេឌីតសរុបនៃការអប់រំជំនាញមានដូចខាងក្រោម :

ក. បរិញ្ញាប័ត្រ ៤ឆ្នាំ : ចំនួនក្រេឌីតសរុបមិនត្រូវតិចជាង ៩០ក្រេឌីត សំរាប់មុខវិជ្ជាជំនាញ (Major Subjects) និងមុខវិជ្ជាគួបផ្សំ (Minor Subjects) ។

ខ. បរិញ្ញាប័ត្រ ៥ឆ្នាំ : ចំនួនក្រេឌីតសរុបមិនត្រូវតិចជាង ១១០ក្រេឌីត សំរាប់មុខវិជ្ជាជំនាញ និងមុខវិជ្ជាគួបផ្សំ ។

គ. បរិញ្ញាប័ត្រ ៦ឆ្នាំ : ចំនួនក្រេឌីតសរុបមិនត្រូវតិចជាង ១៣០ក្រេឌីត សំរាប់មុខវិជ្ជាជំនាញ និងមុខវិជ្ជាគួបផ្សំ ។

ចំនួនក្រេឌីតសរុបនៃការអប់រំជំនាញមិនរាប់បញ្ចូលមុខវិជ្ជាបន្ថែម ចំនេះដឹងទូទៅ ផ្នែកកុំព្យូទ័រ ផ្នែកភាសាបរទេស និងផ្នែកផ្សេងទៀត ។ ចំនួនក្រេឌីតសរុបខាងលើរាប់បញ្ចូលទាំងមុខវិជ្ជាដែលនិស្សិតអាចជ្រើសរើសដោយសេរី ពីកម្មវិធីសិក្សាណាមួយ នៅក្នុងកម្មវិធីសិក្សាថ្នាក់បរិញ្ញាប័ត្រដែលបណ្តុះបណ្តាលនៅក្នុងគ្រឹះស្ថានឧត្តមសិក្សានោះ ។ មុខវិជ្ជាជ្រើសរើសមិនត្រូវតិចជាង ៣ក្រេឌីត ។

## ជំពូកទី៤
## ការចុះឈ្មោះចូលរៀន

**ប្រការ១៤** : និស្សិតសិក្សាពេញម៉ោង គឺនិស្សិតដែលចុះឈ្មោះចូលរៀនគ្រប់មុខវិជ្ជាទាំងអស់ នៃឆមាសទីមួយៗ ដែលកំណត់ដោយសាមីគ្រឹះស្ថានឧត្តមសិក្សា ។

**ប្រការ១៥** : និស្សិតសិក្សាមិនពេញម៉ោង គឺនិស្សិតដែលចុះឈ្មោះចូលរៀនមិនគ្រប់មុខវិជ្ជាទាំងអស់ នៃឆមាសទីមួយៗ ដែលកំណត់ដោយសាមីគ្រឹះស្ថានឧត្តមសិក្សា ។

**ប្រការ១៦** : និស្សិតពេញម៉ោងត្រូវចុះឈ្មោះចូលរៀនមិនតិចជាង ១២ក្រេឌីត និងមិនត្រូវច្រើនជាង ២១ក្រេឌីត នៅក្នុងឆមាសនីមួយៗ ។ និស្សិតមិនពេញម៉ោងត្រូវចុះឈ្មោះចូលរៀនមិនតិចជាង ៦ក្រេឌីត និងមិនត្រូវច្រើនជាង ១៨ ក្រេឌីត នៅក្នុងឆមាសនីមួយៗ ។

**ប្រការ១៧** : គោលការណ៍សំរាប់ការបញ្ចប់ការសិក្សា មានដូចខាងក្រោម :

ក. ថ្នាក់បរិញ្ញាប័ត្រ ៤ឆ្នាំ : និស្សិតពេញម៉ោង មិនអាចបញ្ចប់ការសិក្សាមុនរយៈពេល ៦ឆមាស និងត្រូវតែបញ្ចប់ការសិក្សាមិនឱ្យលើសពី ១២ឆមាស ។ និស្សិតមិនពេញម៉ោងត្រូវតែបញ្ចប់ការ

សិក្សាមិនឱ្យលើសពី ១៦ឆមាស ។

ខ. ថ្នាក់បរិញ្ញាបត្រ ៥ឆ្នាំ : និស្សិតពេញម៉ោង មិនអាចបញ្ចប់ការសិក្សាមុនរយៈពេល ៨ឆមាស និងត្រូវតែបញ្ចប់ការសិក្សាមិនឱ្យលើសពី ១៤ឆមាស ។ និស្សិតមិនពេញម៉ោង ត្រូវតែបញ្ចប់ការសិក្សាមិនឱ្យលើសពី ២០ឆមាស ។

គ. ថ្នាក់បរិញ្ញាបត្រ ៦ឆ្នាំ : និស្សិតពេញម៉ោង មិនអាចបញ្ចប់ការសិក្សាមុនរយៈពេល ១០ឆមាស និងត្រូវតែបញ្ចប់ការសិក្សាមិនឱ្យលើសពី ១៦ឆមាស ។ និស្សិតមិនពេញម៉ោង ត្រូវតែបញ្ចប់ការសិក្សាមិនឱ្យលើសពី ២៤ឆមាស ។

ចំពោះគ្រឹះស្ថានឧត្តមសិក្សា ដែលធ្វើការបណ្តុះបណ្តាលនៅក្នុងវិស្សមកាល និស្សិតម្នាក់ៗមិនត្រូវបានអនុញ្ញាតឱ្យចុះឈ្មោះសិក្សាលើសពី ៩ក្រេឌីត ឡើយ ។

## ជំពូកទី៥
## ប្រព័ន្ធផ្តល់ពិន្ទុ និង និទ្ទេស

**ប្រការ១៨** : និស្សិតម្នាក់ៗត្រូវតែបញ្ចប់មុខវិជ្ជានីមួយៗ ដែលតំរូវនៅក្នុងកម្មវិធីសិក្សានៃគ្រឹះស្ថានឧត្តមសិក្សាណាមួយ ។ ប្រព័ន្ធផ្តល់ពិន្ទុ និង និទ្ទេសមានដូចខាងក្រោម :

| **ពិន្ទុជាភាគរយ** (Mark Obtained, %) | **និទ្ទេសជាអក្សរ** (Grade) | **ពិន្ទុនិទ្ទេស** (GradePoint) | **អត្ថន័យនិទ្ទេស** (Meaning) |
|---|---|---|---|
| 85%-100% | A | 4.00 | Excellent |
| 80%-84% | $B^+$ | 3.50 | Very Good |
| 70%-79% | B | 3.00 | Good |
| 65%-69% | $C^+$ | 2.50 | Fairly Good |
| 50%-64% | C | 2.00 | Fair |
| 45%-49% | D | 1.50 | Poor |
| 40%-44% | E | 1.00 | Very Poor |
| < 40% | F | 0.00 | Failure |

គ្រឹះស្ថានឧត្តមសិក្សាណាមួយ ដែលមានប្រព័ន្ធផ្តល់ពិន្ទុ និង និទ្ទេសផ្សេងពីខាងលើគ្រឹះស្ថានឧត្តមសិក្សានោះ ត្រូវតែបញ្ជាក់ពីប្រព័ន្ធនោះ ដែលអាចប្រៀបធៀបជាមួយប្រព័ន្ធខាងលើ ។ មធ្យមភាគនៃពិន្ទុនិទ្ទេសសរុប (Grade Point Average-GPA) ដែលកំនត់ថាជាប់ គឺចាប់ពី២ឡើងទៅ ។ ចំពោះពិន្ទុនិទ្ទេសនៃមុខវិជ្ជាជំនាញ ដែលកំនត់ថាជាប់គឺចាប់ពី ២ឡើងទៅ ។

**ប្រការ១៩** : រូបមន្តគណនារកមធ្យមនៃពិន្ទុនិទ្ទេសសរុប (GPA) គឺ : មធ្យមភាគនៃពិន្ទុនិទ្ទេសសរុប (GPA) ស្មើផលបូកសរុបរវាងផលគុណ នៃពិន្ទុនិទ្ទេស (Grade Point-P) និង តំលៃក្រេឌីត ដែលត្រូវយកនៃមុខវិជ្ជានីមួយៗ (Attempted Credit Value-C) ចែកនឹងផលបូកសរុបនៃ តំលៃក្រេឌីតដែលត្រូវយកគ្រប់មុខវិជ្ជា ។

$$GPA = \frac{\sum (P \times C)}{\sum C}$$

## ជំពូកទី៦
## ការផ្ទេរក្រេឌីត

**ប្រការ២០** : គ្រឹះស្ថានឧត្តមសិក្សានីមួយៗ ត្រូវទទួលស្គាល់ក្រេឌីត ពីគ្រឹះស្ថានឧត្តមសិក្សាមួយផ្សេងទៀត ដែលមានការទទួលស្គាល់គុណភាពអប់រំ ។ ក៏ប៉ុន្តែការសំរេចចុងក្រោយទាក់ទងទៅនឹងការផ្ទេរ ក្រេឌីតនេះជាសិទ្ធិរបស់គ្រឹះស្ថានឧត្តមសិក្សា ដែលជាអ្នកទទួលយកក្រេឌីតនោះប៉ុណ្ណោះ ។

ដើម្បីសំរួលដល់ដំណើរការនៃការផ្ទេរក្រេឌីត គ្រឹះស្ថានឧត្តមសិក្សានីមួយៗ :

ក. ត្រូវចេញព្រឹត្តប័ត្រពិន្ទុដល់និស្សិត ដោយបញ្ជាក់ឱ្យបានច្បាស់លាស់នូវមុខវិជ្ជា ដែលនិស្សិតបានសិក្សា ចំនួនក្រេឌីត ពិន្ទុនៃមុខវិជ្ជានីមួយៗ និងសេចក្តីពន្យល់លំអិតដែលពាក់ព័ន្ធទៅនឹងការផ្តល់ពិន្ទុ និង និទ្ទេសតាមសំណើរបស់និស្សិត ។

ខ. ត្រូវកំនត់លក្ខខណ្ឌឱ្យបានច្បាស់លាស់ សំរាប់ការទទួលយកក្រេឌីត ពីគ្រឹះស្ថានឧត្តមសិក្សា មួយផ្សេងទៀត ។

គ. អាចទទួលយកតំលៃក្រេឌីតនៃមុខវិជ្ជាណា ដែលនិស្សិតបានបញ្ចប់ការសិក្សា ដោយជោគជ័យ នៅក្នុងគ្រឹះស្ថានឧត្តមសិក្សាមួយផ្សេងទៀត ។

## ជំពូកទី៧

## អវសានប្បញ្ញត្តិ

**ប្រការ២១ :** អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា គ្រប់គ្រឹះស្ថានឧត្តមសិក្សា និងគ្រប់ស្ថាប័នពាក់ព័ន្ធត្រូវអនុវត្តសេចក្តីសំរេចនេះ ឱ្យមានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ២០០៤

**ជ. ប្រធាន គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា**

**អនុប្រធានអចិន្ត្រៃយ៍**

**សុខ-អាន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេច-ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី
- គ្រប់សមាជិក គ.ទ.ក
- គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ
- ក្រសួងអប់រំយុវជន និងកីឡា

  "ដើម្បីជ្រាបជាព័តិមាន"
- គ្រប់គ្រឹះស្ថានឧត្តមសិក្សា

  "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ